ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**អគ្គនាយកដ្ឋានពន្ធដារ**

លេខ.....២៦៣៤៣...អពដ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

L202307150005TD2519

ថ្ងៃពុធ ០១រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣

**ជម្រាបជូន**

**លោក ឈឹម ច័ន្ទប្រាថ្នា**

**អគ្គនាយក ក្រុមហ៊ុន មេហ្គាប្រ៊ីដ (ខេមបូឌា) ឯ.ក**

**កម្មវត្ថុ** ៖ ស្តីពីការអញ្ជើញលោក ឈឹម ច័ន្ទប្រាថ្នា ចូលខ្លួនមកទូទាត់បំណុលពន្ធ។

**យោង** ៖-ច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣

-ប្រកាសលេខ ៩៦២ សហវ.ប្រក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងបំណុលពន្ធដារ។

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមជម្រាបជូនលោកអគ្គនាយកក្រុមហ៊ុន មេហ្គាប្រ៊ីដ (ខេមបូឌា) ឯ.ក (MEGABRIDGE (CAMBODIA) CO.,LTD) លេខអត្តសញ្ញាណកម្មសារពើពន្ធ៖ K007-901701362 ចុះបញ្ជីនៅសាខាពន្ធដារខណ្ឌមានជ័យ ឱ្យបានជ្រាបថា ការបង់ពន្ធអាករគឺជាកាតព្វកិច្ចរបស់អ្នកជាប់ពន្ធគ្រប់រូប ដើម្បីរួមចំណែកក្នុងថវិកាជាតិ។ កន្លងមក អគ្គនាយកដ្ឋានពន្ធដារបានអញ្ជើញលោកអគ្គនាយកមកដើម្បីដោះស្រាយបំណុលពន្ធ តាមរយៈលិខិតអញ្ជើញលេខ ៣៩៦៧ អពដ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ប៉ុន្តែម្ចាស់ក្រុមហ៊ុនមិនបានទូទាត់បំណុលពន្ធតាមនីតិវិធីច្បាប់។

អនុលោមតាមវាក្យខណ្ឌ ខ នៃកថាខណ្ឌទី៦ នៃមាត្រា ១៩៨ នៃច្បាប់ស្តីពីសារពើពន្ធ អគ្គនាយកដ្ឋានពន្ធដារ សូមអញ្ជើញលោកអគ្គនាយក មកនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម នៃអគ្គនាយកដ្ឋានពន្ធដារ អគារ FLATIRON ជាន់ទី១៩ ផ្លូវលេខ១០២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ លេខទូរស័ព្ទទំនាក់ទំនង ០៨៦ ៦៩៦ ៣៣៣ មិនឱ្យលើសពី ១៥ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទលើលិខិតអញ្ជើញក្នុងទំព័រសារព័ត៌មាននេះ ដើម្បីដោះស្រាយបំណុលពន្ធរង្គ។

ក្នុងករណី មិនបានអញ្ជើញមកតាមកាលកំណត់ខាងលើនេះទេ លោកអគ្គនាយកត្រូវចាត់ទុកថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចមានចែងក្នុងមាត្រា ២២៦ ២៤២ និង ២៤៣ នៃច្បាប់ស្តីពីសារពើពន្ធ ហើយអគ្គនាយកដ្ឋានពន្ធដារ នឹងចាត់វិធានការដោយប្តឹងទៅតុលាការដើម្បីផ្តន្ទាទោសតាមច្បាប់ជាធរមាន។

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមជឿជាក់លើស្មារតីទទួលខុសត្រូវខ្ពស់របស់លោកអគ្គនាយក ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធឱ្យបានត្រឹមត្រូវ។

**អគ្គនាយកដ្ឋានពន្ធដារ**

ព្រះរាជាណាចក្រកម្ពុជា * អគ្គនាយកដ្ឋានពន្ធដារ * ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ចម្លងជូន៖**

- ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ *(ដើម្បីជូនជ្រាប)*
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម *(ដើម្បីតាមដាន និងមុខការ)*
- សាខាពន្ធដារខណ្ឌមានជ័យ
- ឯកសារ-កាលប្បវត្តិ